ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សារលិខិតអបអរសាទរ
# ខួបលើកទី៤២ នៃទិវាជ័យជំនះ ៧មករា

## សូមគោរពជូន
## សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចវិបុលសេនាភក្តី ជាទីគោរពដ៏ខ្ពង់ខ្ពស់**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយឥតឧបមាចំពោះខួបលើកទី៤២ នៃទិវាជ័យជំនះ ៧មករា ដែលជាថ្ងៃរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីការកាប់សម្លាប់ក្នុងមហាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបើកឡើងវិញសករាជថ្មីនៃកម្ពុជា។

យើងខ្ញុំសូមសម្តែងនូវអំណរសាទរ ប្រកបដោយកតញ្ញូកតវេទិត្តាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចវិបុលសេនាភក្តី** ដែលក្រោមការដឹកនាំប្រកបដោយបញ្ញាញាណដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចវិបុលសេនាភក្តី** បានធ្វើឲ្យស្ថាប័នព្រឹទ្ធសភា ដែលជាស្ថាប័ននីតិបញ្ញត្តិកំពូលរបស់ជាតិ សម្រេចបាននូវសមិទ្ធិផលធំៗជាច្រើន រួមចំណែកយ៉ាងសំខាន់ដល់ការរក្សាបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍឥតឈប់ឈរ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **សម្តេចវិបុលសេនាភក្តី លោកជំទាវ បុត្រា បុត្រី និង ចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃពុធ ៨រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិតោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh